ELBBL

English Language Based Bachelor of Law Program

R.U.L.E

LAW CLINIC

RULE - English Language Based Bachelor of Law (ELBBL) Program

# នីតិវិធីឃុំខ្លួនបណ្ដោះអាសន្ន

# អនីតិជននៅកម្ពុជា

# មាតិកា

០១ អំពីយើង
០២ អ្វីទៅជាការឃុំខ្លួនបណ្តោះអាសន្ន ?
០៣ កាតព្វកិច្ច និងទំនួលខុសត្រូវរបស់អនីតិជន
០៤ កាតព្វកិច្ច និងទំនួលខុសត្រូវរបស់សមត្ថកិច្ច
០៥ លក្ខខណ្ឌក្នុងការដោះលែងពីការឃុំខ្លួន
០៦ គុណប្រយោជន៍ការយល់ដឹងអំពីការឃុំខ្លួនបណ្តោះអាសន្ន
០៧ សរុបសេចក្តី

# ០១. អំពីយើង

ELBBL
English Language Based Bachelor of Law Program
R.U.L.E



កញ្ញា ហ៊ីង វ៉ាន់ដាណែត
សាស្ត្រាចារ្យ

LAW CLINIC
RULE - English Language Based Bachelor of Law (ELBBL) Program



កញ្ញា សូ ឡៃនធីតា
សមាជិក



កញ្ញា រុធ វិដ្ឋ៉ា
សមាជិក



កញ្ញា ប៊ុន សុបុញ្ញតា
Member



លោក អ៊ុក សុវណ្ណឫទ្ធិ
សមាជិក



លោក សុភាព ដារ៉ាវីន
សមាជិក

ELBBL
English Language Based Bachelor of Law Program
R.U.L.E

LAW CLINIC
RULE - English Language Based Bachelor of Law (ELBBL) Program

# ០២. អ្វីទៅជាការឃុំខ្លួនបណ្ដោះអាសន្ន?

# អ្វីទៅជាការឃុំខ្លួនបណ្ដោះអាសន្ន ?

ការឃុំខ្លួនបណ្ដោះអាសន្នគឺ ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្ដី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ។



- ការឃុំខ្លួនបណ្ដោះអាសន្ន, ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, https://ciclg.com/kh/article/128

# ដំណាក់កាលនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនជាបណ្តោះអាសន្ននេះ គឺត្រូវបានធ្វើឡើង បន្ទាប់ពីការបើកស៊ើបសួរបឋមរួចហើយ ចៅក្រមស៊ើបសួរយល់ឃើញថា៖ ជនត្រូវចោទនោះមានតម្រុយនៃពិរុទ្ធភាពនោះ ចៅក្រមស៊ើបសួរគាត់ជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ទៅលើជនត្រូវចោទនោះ និងដើម្បីរៀបចំបញ្ជូនសំណុំរឿងទៅតុលាការជំនុំជម្រះ។



# តើមានដំណាក់កាលអ្វីខ្លះទើបអាចឈានចូលដល់ការឃុំខ្លួនបណ្តោះអាសន្ន?

មន្ត្រីនគរបាលយុត្តិធម៌ឃាត់ខ្លួនជនសង្ស័យនៅពេលមានតម្រុយដែលបង្ហាញឱ្យឃើញថាមានពិរុទ្ធភាពលើជននោះ ដោយរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា រួមជាមួយនឹងភស្តុតាងទាំងអស់។

ព្រះរាជអាជ្ញាពិនិត្យទៅបទល្មើសរបស់ជនសង្ស័យនោះ ដោយវាយតម្លៃភស្តុតាងដែលបង្ហាញដោយមន្ត្រីនគរបាលយុត្តិធម៌។

នៅពេលផុតកំណត់នៃរយៈពេលឃាត់ខ្លួន បុគ្គលដែលត្រូវបានឃាត់ខ្លួននោះត្រូវៈបញ្ជូនខ្លួនទៅព្រះរាជអាជ្ញ ឬ ដោះលែងឱ្យមានសេរីភាពឡើងវិញ ដោយសេចក្តីសម្រេចនេះធ្វើឡើងដោយព្រះរាជអាជ្ញា។



# ការឃុំខ្លួនបណ្ដោះអាសន្ន

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្ដោះអាសន្ន ដោយគំនិតផ្ដើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ នឹងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ។

កាលណាជនត្រូវចោទមានមេធាវីនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។ ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នតាមដីកាដោយមានសំអាងហេតុ នៅក្នុងដីកានេះចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ។



## ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានបង្គាប់កាលណា ការឃុំខ្លួនបណ្តោះអាសន្ននេះ វាជាការចាំបាច់ ៖

- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី
- ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត
- ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
- ដើម្បីធានារក្សាជនត្រូវចោទ សម្រាប់តុលាការចាត់ការតាមនីតិវិធី
- ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ។
- ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស៕




- មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# ០៣. ភាតព្វកិច្ច និង ទំនួលខុសត្រូវរបស់ អនីតិជន

| រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋរបស់នីតិជន | រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងសំណុំរឿងបទមជ្ឈិមនីតិជន |
| --- | --- |
| • ចំពោះនីតិជនការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋនឹងមិនលើសពី(ប្រាំមួយ)៦ខែឡើយ ប៉ុន្តែនៅពេលដែលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន៦(ប្រាំមួយ)ខែ។<br>• ការពន្យារពេលឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ដងបានទេ។ | • ចំពោះនីតិជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសមជ្ឈិមការឃុំខ្លួនបណ្ដោះអាសន្ននឹងមិនលើសពី៤(បួន)ខែ<br>• ប៉ុន្តែពេលដែលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនតែ១លើកប៉ុណ្ណោះនិងមិនយូរជាង២ (ពីរ) ខែ។<br>• រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះនឹងមិនលើសពីពាក់កណ្ដាលនៃទោសអប្បបរមាកំណត់ដោយច្បាប់។ |

(មាត្រា ២០៨, ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)





តើអនីតិជនត្រូវមានកាតព្វកិច្ចដូចម្តេចខ្លះនៅក្រោមច្បាប់ព្រហ្មទណ្ឌ?

តើអនីតិជនត្រូវបានឃុំខ្លួនក្នុងរយៈពេលប៉ុន្មានដែរ?



(មាត្រា២១១ & ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

<table>
<tr><th>រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋដែលប្រព្រឹត្តដោយអនីតិជនចាប់ពី ១៤ ដល់ក្រោម ១៨ ឆ្នាំ</th><th>រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទល្មើសមជ្ឈិមដែលប្រព្រឹត្តដោយអនីតិជនចាប់ពី ១៤ ដល់ក្រោម ១៨ ឆ្នាំ</th></tr>
<tr><td>១. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើស ពី ៤ (បួន) ខែ បើ អនីតិជន មាន អាយុ ក្រោម ១៦ ឆ្នាំ(ដប់ប្រាំមួយ)។</td><td>១. ឃុំខ្លួនបណ្ដោះអាសន្ន មិអាចលើសពី២(ពីរ)ខែបើអនីតិជន ស្ថិតក្រោម (ដប់ ប្រាំមួយ)អាយុ ១៦ ឆ្នាំ។</td></tr>
<tr><td>២. ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី៦ (ប្រាំមួយ) ខែ បានទេ ប្រសិនបើអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ(ដប់ប្រាំមួយ) អាយុ១៨ឆ្នាំ(ដប់ប្រាំបី) ឆ្នាំ។</td><td>២. ឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី៤ (បួន) ខែបានទេ បើអនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ(ដប់ប្រាំមួយ) និងអាយុតិចជាង១៨(ដប់ប្រាំបី) ឆ្នាំ។</td></tr>
<tr><td colspan="2">អនីតិជន អាយុ ក្រោម ១៤ ឆ្នាំ (ដប់បួន) ឆ្នាំ មិនអាចដាក់នៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នបានទេ។ ចៅក្រមស៊ើបសួរអាច សម្រេចប្រគល់អនីតិជនទៅឲ្យឪពុក ម្ដាយ អាណាព្យាបាល របស់គេ វិញ ឬ បើ គ្មាន អាណាព្យាបាលនោះអនីតិជន នឹង ត្រូវ ប្រគល់ទៅឲ្យ មជ្ឈមណ្ឌល អប់រំ និងថែទាំ បណ្ដោះអាសន្ន រង់ចាំ ការ សម្រេច របស់ តុលាការ។</td></tr>
</table>

# មូលហេតុក្នុងការឃាត់ខ្លួនអនីតិជន

- មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំបានប្រសិនបើជឿជាក់ថា៖
  - អនីតិជនអាចរត់គេចខ្លួន
  - ឬ បំផ្លាញភស្តុតាង
  - ឬ បង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ
  - ឬ សន្តិសុខសាធារណៈ
  - ឬ ក្នុងគោលបំណងសុវត្ថិភាពអនីតិជននោះ

- លើសពីនេះ អនីតិជនអាយុ ១៤ ដល់ក្រោម ១៦ឆ្នាំ ការឃាត់ខ្លួនអនីតិជនអាចធ្វើបានក្នុងករណីប្រព្រឹត្តបទល្មើស ឧក្រិដ្ឋ ឬមជ្ឈិមចេតនា។



| ការឃាត់ខ្លួននីតិជន | ការឃាត់ខ្លួនអនីតិជន |
| --- | --- |
| • ការឃាត់ខ្លួនមានថេរវេលា ៤៨(សែសិបប្រាំបី) ម៉ោង<br>• ថិរវេលាត្រូវគិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអវុធហត្ថ។<br> | • អនីតិជនអាយុពី ១៤ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ អាចត្រូវបានឃាត់ខ្លួន<br>- មិនឲ្យហួស ៣៦ម៉ោង ក្នុងបទឧក្រិដ្ឋ<br>- មិនឲ្យហួស ២៤ម៉ោង ក្នុងបទមជ្ឈិម<br>• អនីតិជនអាយុ ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ អាចត្រូវបានឃាត់ខ្លួន<br>- មិនត្រូវហួស ៤៨ម៉ោង ក្នុងបទឧក្រិដ្ឋ<br>- មិនត្រូវហួស ៣៦ម៉ោង ក្នុងបទមជ្ឈិម<br>• អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនឡើយ។ |

(មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)



| <u>ការពន្យាពេលឃាត់ខ្លួននីតិជន</u> | <u>ការពន្យារពេលឃាត់ខ្លួនអនីតិជន</u> |
| --- | --- |
| • ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញអោយឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីអោយការសើបអង្កេតប្រព្រឹត្តទៅបានល្អ<br><br>• ការពន្យារគឺជាវិធានការពិសេស ហើយការពន្យារនេះមិនអាចអោយលើសពី ២៤ ( ម្ភៃបួន ) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។ | • ការពន្យារពេលមិនអាចត្រូវយល់ព្រមបានទេប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។ |

(មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ELBBL
English Language Based Bachelor of Law Program
R.U.L.E

LAW CLINIC
RULE - English Language Based Bachelor of Law (ELBBL) Program

# ០៤. កាតព្វកិច្ច និង ទំនួលខុសត្រូវរបស់ នគរបាលយុត្តិធម៌

# សំណួរ

១.តើនគរបាលយុត្តិធម៌ត្រូវមានសមត្ថកិច្ចយ៉ាងដូចម្តេចខ្លះចំពោះអនីតិជននៅក្រោមច្បាប់?

២.តើសិទ្ធិអ្វីខ្លះដែលអនីតិជនត្រូវទទួលបានក្នុងកំឡុងពេលឃាត់ខ្លួន?

៣.តើសកម្មភាពអ្វីខ្លះដែលនគរបាលយុត្តិធម៌មិនគួរប្រព្រឹត្តលើអនីតិជន?

# សមត្ថកិច្ចរបស់នគរបាលយុត្តិធម៌

## ក្នុងករណីបទលហុ

- អប់រំណែនាំ រួចប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់
- ធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ
- ធ្វើរបាយការណ៏ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់




(មាត្រា១៣ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន)

# សមត្ថកិច្ចរបស់នគរបាលយុត្តិធម៌

## ក្នុងករណីបទមជ្ឈិម និងបទឧក្រិដ្ឋ

- នគរបាលយុត្តិធម៌ជំនាញ មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម កំណត់អត្តសញ្ញាណ និងចាប់អនីតិជន ព្រមទាំងប្រមូលភស្តុតាង។
- ប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពជំនាញ



(មាត្រា១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន)

# សិទ្ធិដែលអនីតិជនត្រូវទទួលបាននៅពេលស្តាប់ចម្លើយ

- អនីតិជនត្រូវទទួលបានឱកាសសន្ទនា ឬទំនាក់ទំនងជាមួយអ្នកជំនាញ បន្ទាប់ពីរយៈពេល ២៤ ម៉ោង បានកន្លងផុតទៅ

- អនីតិជនត្រូវដឹងអំពីសិទ្ធិជាមូលដ្ឋានមុនពេលស្តាប់ចម្លើយ

- អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយ និងអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ




(មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២១,២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន)

# សកម្មភាពដែលនគរបាលយុត្តិធម៌មិនគួរប្រព្រឹត្តលើអនីតិជន

- មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញជាជួរឡើយ
- អនីតិជនដែលឃាត់ខ្លួនត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងទៅតាមភេទ
- អនីតិជនមិនត្រូវទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ។








(មាត្រា២៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន)

ELBBL
English Language Based Bachelor of Law Program
R.U.L.E

LAW CLINIC
RULE - English Language Based Bachelor of Law (ELBBL) Program

# ០៥. លក្ខខណ្ឌក្នុងការដោះលែងពីការឃុំខ្លួន



# តើអនីតិជនត្រូវបានដោះលែងដោយលក្ខខណ្ឌអ្វីខ្លះ?

R.U.L.E
ELBBL
English Language Based
Bachelor of Law Program

LAW CLINIC
RULE - English Language Based
Bachelor of Law (ELBBL) Program

# ០៦. គុណប្រយោជន៍នៃ ការយល់ដឹងអំពីការឃុំ ខ្លួនបណ្ដោះអាសន្ន



១. ដឹងអំពីសិទ្ធិ



២. ដឹងអំពីជំនួយ



៣. ដឹងអំពីផលប៉ះពាល់




១. ដឹងអំពីសិទ្ធិ៖ សិទ្ធិមិនត្រូវបានទារុណកម្ម បង្ខិតបង្ខំ គំរាមកំហែង បំភិតបំភ័យ ឬរាល់សកម្មភាពដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់អនីតិជន។ ។

**This also Support by the Convention on the Rights of the Children hereinafter (CRC) ratified by Cambodia in 1992:**

**Article 37 has expressed that no child must ever be tortured or subjected to any other form of cruel, inhuman, or cruel punishment or treatment**

មាត្រា ២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ



# ករណី ក្មេងស្រី ចាន់ លីណា

## ២. ដឹងអំពីជំនួយ៖

ជំនួយក្នុងដែន៖ សមាជិកគ្រួសារ មិត្តភក្តិ មនុស្សជុំវិញខ្លួន

ជំនួយក្រៅដែន៖ UNICEF, CNCC, COCD, NGO



# ជំនួយអាចជានរណា?

អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍, ចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ឆ្នាំ២០០៨ និងត្រូវបានទទួលស្គាល់ និងបញ្ជាក់ពីរដ្ឋាភិបាលកម្ពុជា ជាអង្គការសុវត្ថិភាពកុមារ ឆ្នាំ២០១២។

Link:https://cocd-cambodia.org/en/#:~:text=Welcome%20to%20COCD%20Cambodia&text=Mission%3A%20COCD%20aims%20to%20improve,social%20exclusion%20and%20child%20abuse.

យូនីសេហ្វ កម្ពុជា ជាអង្គការបង្កើតឡើងតាំងពី ឆ្នាំ១៩៥២ ដើម្បីការពារសិទ្ធិកុមារកម្ពុជា។

Link: https://www.unicef.org/cambodia/child-protection

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ២១ ធ្នូ ២០០៩។

Link: https://www.cambodiayp.com/company/7371/CNCC_Cambodia_National_Council_for_Children#:~:text=The%20Royal%20Government%20of%20Cambodia,survival%2C%20development%2C%20protection%2C%20improve



៣. ដឹងអំពីផលប៉ះពាល់៖

ផ្លូវកាយ

ផ្លូវអារម្មណ៍

កិត្តិយស

ចំណេះដឹងនិងការលូតលាស់

ផ្លូវកាយ៖ យោងតាម This Life NGO វេបសាយ នៅចុងឆ្នាំ 2019 53% នៃកុមារទាំងអស់ ដែលក្នុងនោះ 77% ជាកុមារីបានជាប់គុកដោយសារឧក្រិដ្ឋកម្មទាក់ទងនឹងគ្រឿងញៀន (ជាអ្នកប្រើប្រាស់ ជាអ្នកដឹកជញ្ជូន ឬជាចោរកម្ម)។ សរុបមក កុមារមានប្រមាណ ៤.៥% នៃចំនួនអ្នកទោសសរុបនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែខេត្តសៀមរាបមានអត្រាអ្នកទោសកុមារខ្ពស់ជាងខេត្តដទៃទៀត ដែលមានកុមារមានជិត ១៣% នៃចំនួនអ្នកទោស។

ការឃុំខ្លួនកុមារ អាចធ្វើអោយកុមារប្រឈមនឹងការទទួលរងអំពើហឹង្សា និងកង្វះនៃការថែទាំ និងពិសេសអាចទទួលរងការរំលោភបំពាន។

ផ្លូវអារម្មណ៍៖ កុមារប្រៀបបានក្រដាសស ដែលពណ៌ណា ដែលយើងផាត់នៅលើពួកគេ វានឹងជឺតជាប់លើពួកគេ។ វានឹងឆ្លាក់ជាប់នៅលើគំនិត និងការចងចាំរបស់ពួកគេ។ នៅបរទេស ក្មេងម្នាក់ឈ្មោះ ជូលីអូ បានចំណាយពេល ១១ខែក្នុងការឃុំឃាំងបណ្ដោះអាសន្ន ដោយបទសង្ស័យមួយ ហើយប៉ូលីសបានធ្វើទារុណកម្ម ដើម្បីបានចម្លើយពីកុមារម្នាក់នោះ។ ក្រោយពីរកឃើញថាគេមិនមែនជាជនជាប់ចោទ គេក៏បានត្រូវដោះលែង តែ.... ជីវិតកុមារនោះក៏បានផ្លាស់ប្តូរដោយគេមានជំងឺផ្លូវអារម្មណ៍ដែលបានប៉ះទង្គិច។





កិត្តិយស៖ អាចទទួលបានការប្រមាថ ម៉ាក់ងាយ និងមិនឱ្យតម្លៃពីមនុស្សជុំវិញខ្លួន

ចំណេះដឹង និងការលូតលាស់៖ ការឃុំខ្លួនបណ្តោះអាសន្ន នឹងបង្អាក់ការទទួលបានចំណេះដឹងរបស់អនីតិជន និងការឃុំខ្លួននេះក៏អាចផ្តល់បទពិសោធន៍ដ៏អវិជ្ជមានដែលអាចប៉ះពាល់ដល់អត្តចរិត និងការលូតលាស់ផ្នែកសង្គមរបស់អនីតិជនដែរ ព្រោះដោយសារការដាក់ដោយឡែកពីសង្គម។

# ០៧. សន្និដ្ឋាន

(Title as printed on the slide: ០៧. សរុបសេចក្តី)

ការឃុំខ្លួនមិនថាលើអនីតិជន ឬនីតិជន ត្រូវតែជាជម្រើសចុងក្រោយ និងមានរយៈពេលខ្លី។

អនីតិជនដែលស្ថិតក្រោមការឃុំខ្លួន គួរត្រូវបានច្បាប់ការពារឱ្យបានតឹងរឹង ព្រោះពួកគេងាយនឹងត្រូវបានរំលោភបំពានសិទ្ធិ។

# សូមអរគុណ